# គម្រោង សន្សំជាក្រុម

(១) អត្រាការប្រាក់លម្អិត៖

| សមតុល្យសរុបប្រចាំថ្ងៃ ដុល្លារ (សមមូលប្រាក់រៀល) | អត្រាការប្រាក់ (ប្រចាំឆ្នាំ) | |
|---|---|---|
| | ដុល្លារ | រៀល |
| > ៥០០ – ១.០០០ | ០,៧០% | ១,២០% |
| > ១.០០០ – ៣.០០០ | ០,៩០% | ១,៤០% |
| > ៣.០០០ – ៥.០០០ | ១,៥០% | ២,០០% |
| > ៥.០០០ – ១០.០០០ | ២,០០% | ២,៥០% |
| > ១០.០០០ | ២,២៥% | ២,៧៥% |

(២) លក្ខខណ្ឌ

លក្ខខណ្ឌទាំងនេះ អនុវត្តចំពោះនិងគ្រប់គ្រងរាល់ប្រតិបត្តិការនៃផលិតផល "គម្រោងសន្សំជាក្រុម" ដែលផ្តល់ជូនដោយធនាគារស្ថាបនា។

**លក្ខខណ្ឌទូទៅ៖**

- គម្រោងសន្សំជាក្រុម អាចបង្កើតឡើងដោយតម្រូវឱ្យមានសមាជិកយ៉ាងតិចពីរនាក់ និងអតិបរមាប្រាំនាក់
- គណនីមួយរបស់អតិថិជនម្នាក់ អាចចូលរួមគម្រោងសន្សំជាក្រុមបានតែមួយក្រុមប៉ុណ្ណោះ
- គណនីបញ្ញើសន្សំបុគ្គលទាំងអស់ រួមទាំងនិវាសនជន និងអនិវាសនជន អាចចូលរួមគម្រោងសន្សំជាក្រុមនេះបាន
- គណនីស្នើសុំដែលបានដាក់បញ្ចូលក្នុងគម្រោងសន្សំជាក្រុម ត្រូវតែជាគណនីសកម្ម
- ប្រសិនបើគណនីណាមួយក្លាយជាគណនីអសកម្មបន្ទាប់ពីចូលរួមគម្រោងសន្សំជាក្រុម គណនីនោះនឹងមិនទទួលបានអត្រាការប្រាក់បន្ថែមនោះឡើយ។ អត្រាការប្រាក់បន្ថែម នឹងត្រូវបានអនុវត្តចំពោះតែគណនីសកម្មប៉ុណ្ណោះ ហើយនឹងទូទាត់នៅថ្ងៃដដែលជាមួយថ្ងៃទូទាត់ការប្រាក់របស់គណនីលោកអ្នក
- ការកាត់ពន្ធនឹងអនុវត្តតាមប្រភេទ ឬ លក្ខណៈរបស់គណនីនីមួយៗ
- ប្រសិនបើគម្រោងសន្សំជាក្រុម មានសមាជិកនៅសល់តែម្នាក់ អត្រាការប្រាក់បន្ថែមនឹងមិនត្រូវបានផ្តល់ជូនទៀតនោះទេ
- មិនអនុញ្ញាតឱ្យអ្នកណាម្នាក់ក្នុងក្រុម មានសិទ្ធិលុបគណនីសមាជិកណាមួយចេញឡើយ
- ទិន្នន័យហិរញ្ញវត្ថុក្នុងគម្រោងសន្សំជាក្រុម នឹងមិនត្រូវបានចែករំលែក ឬ មិនត្រូវបានចូលពិនិត្យមើល/មិនត្រូវបានធ្វើប្រតិបត្តិការដោយសមាជិកណាម្នាក់នោះឡើយ លើកលែងតែលេខគណនី និងឈ្មោះគណនីរបស់សមាជិកទាំងអស់
- អតិថិជនអាចស្នើសុំឱ្យដាក់ឈ្មោះគម្រោងសន្សំជាក្រុម ទោះយ៉ាងណាក៏ដោយ ឈ្មោះដែលស្នើសុំមិនត្រូវបំពានលើច្បាប់សង្គមនយោបាយ ឬការបៀតបៀនណាមួយឡើយ ហើយវាមិនត្រូវប្រើសម្រាប់គោលបំណងរើសអើង ឬខុសច្បាប់ណាមួយឡើយ។ ប្រសិនបើយើងរកឃើញថាអតិថិជនណាម្នាក់បានបំពានលក្ខខណ្ឌ ធនាគារស្ថាបនារក្សាសិទ្ធិក្នុងការបញ្ឈប់សេវាកម្ម/អត្ថប្រយោជន៍នៅពេលណាក៏បាន ដោយមិនចាំបាច់ជូនដំណឹងជាមុនដល់អតិថិជន
- អតិថិជន យល់ព្រម និងទទួលស្គាល់ថា ឈ្មោះក្រុមដែលបានបង្កើតឡើង មិនអាចកែប្រែបាននោះឡើយ បន្ទាប់ពីបានបង្កើតរួច
- ម្ចាស់ក្រុម និងសមាជិកក្រុមមិនត្រូវបង្កើតប្រាតិភោគណាមួយ ឬការដាក់បញ្ចាំណាមួយ ឬ ការដាក់បន្ទុកណាមួយតាមរយៈការប្រើប្រាស់ឈ្មោះគម្រោងសន្សំជាក្រុមរបស់ខ្លួន សម្រាប់តំណាងឬធានាឱ្យសកម្មភាពអាជីវកម្មរបស់ពួកគេ និងគោលបំណងពាណិជ្ជកម្មណាមួយ និង/ឬការទាមទារសិទ្ធិសម្រាប់គោលបំណងគ្រប់គ្រងហិរញ្ញវត្ថុណាមួយនោះឡើយ។ ឈ្មោះគម្រោងសន្សំជាក្រុមត្រូវបានប្រើសម្រាប់តែការកំណត់ឈ្មោះជាក្រុមតែប៉ុណ្ណោះ។

**ការបញ្ចូល ឬដកគណនីចេញពីគម្រោងសន្សំជាក្រុម ៖**

- នៅពេលបង្កើតគម្រោងសន្សំជាក្រុម សមាជិកទាំងអស់ត្រូវមានវត្តមាននៅធនាគារ ដើម្បីបំពេញបែបបទស្នើសុំ ឬអាចបង្កើតក្រុមតាមរយៈកម្មវិធីស្ថាបនាម៉ូបាលនៅលើទូរស័ព្ទដៃ និងអាចអញ្ជើញសមាជិកតាមរយៈការចែករំលែកការអញ្ជើញតាមឌីជីថល
- សម្រាប់គម្រោងសន្សំជាក្រុមដែលបង្កើតតាមកម្មវិធីស្ថាបនាម៉ូបាលនៅលើទូរស័ព្ទដៃ ប្រសិនបើមិនមានសមាជិកចូលរួមនោះទេ នឹងត្រូវលុបចោលដោយស្វ័យប្រវត្តិក្នុងរយៈពេល ២៤ម៉ោង
- នៅពេលអតិថិជនសម្រេចចិត្តស្នើសុំបង្កើតគម្រោងសន្សំជាក្រុម បុគ្គលណាម្នាក់អាចត្រូវជ្រើសរើសធ្វើជាប្រធានក្រុម

- នៅពេលមានសមាជិកបន្ទាប់មកកាន់សាខាណាមួយរបស់ធនាគារស្ថាបនា ដើម្បីស្នើសុំដាក់គណនីចូលទៅក្នុងគម្រោងសន្សំជាក្រុមណាមួយ សមាជិកបន្ទាប់នោះត្រូវផ្តល់លេខកូដក្រុម/ឈ្មោះក្រុម ហើយសាខានឹងទាក់ទងប្រធានក្រុមសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការយល់ព្រមនោះ
- ប្រសិនបើសមាជិកដែលចាកចេញពីក្រុមគឺជាប្រធានក្រុម គាត់ត្រូវតែជ្រើសរើសប្រធានក្រុមថ្មីមុនពេលចាកចេញពីគម្រោងសន្សំជាក្រុម បន្ទាប់មកត្រូវដាក់ពាក្យស្នើសុំធ្វើបច្ចុប្បន្នភាពប្រធានក្រុម រួមជាមួយនឹងសំណើសុំដកគណនីចេញពីគម្រោងសន្សំជាក្រុមនៅតាមបញ្ជរធនាគារ ឬធ្វើបច្ចុប្បន្នភាពប្រធានក្រុមតាមរយៈកម្មវិធី ស្ថាបនា ម៉ូបាលនៅលើទូរស័ព្ទដៃ  មុនពេលចាកចេញ
- សមាជិកផ្សេងទៀតអាចដកគណនីផ្ទាល់ខ្លួនចេញពីគម្រោងសន្សំក្រុមជា តាមការសម្រេចចិត្តដោយខ្លួនឯង។

## របៀបស្នើសុំ

- សម្រាប់ព័ត៌មានលម្អិត សូមទៅកាន់សាខាណាមួយរបស់ធនាគារ ស្ថាបនា ដែលនៅជិតលោកអ្នកបំផុត អ្នកជំនាញរបស់យើងនឹងស្វាគមន៍ ព្រមទាំងណែនាំលោកអ្នកអំពីដំណើរការនេះ ឬអាចទាក់ទងមកកាន់សហការីរបស់យើងខ្ញុំ ២៤ម៉ោង តាមរយៈលេខទូរស័ព្ទ ០២៣ ៩៩៩ ០១០ / ០៨១ ៩៩៩ ០១០ ឬអ៊ីម៉ែល customercare@sathapana.com.kh ។